ទំនាក់ទំនង: 015 928 585 077 680 908 078 333 998 088 541 6666 1000 x100



# គិតត្រឹមឆ្នាំ២០១៣ ក្រុមហ៊ុនចំនួន២៦ បានចូលទៅធ្វើអាជីវកម្មរ៉ែ នៅខេត្តព្រះវិហារ

( ថ្ងៃទី 26 មករា 2013, ម៉ោង 09:26:AM ) | ដោយ: បាយ៉ន

ក- ក ក+ | Print

Share 0 Google + 0 Tweet 0 Share 0 Email 0



លោក ប៉ុល លឹម ចូលរួមបិទសន្និបាតខេត្តព្រះវិហារ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣

1 of 2

ព្រះវិហារ: តាមតួលេខថ្មីបានឱ្យដឹងថា ខេត្តព្រះវិហារ របស់ព្រះរាជាណាចក្រកម្ពុជា ដែលគេស្គាល់ថា ជាខេត្តមួយសំបូរទៅដោយធនធានរ៉ែច្រើនបំផុតនោះ រហូតមកដល់ឆ្នាំ២០១៣នេះ មានក្រុមហ៊ុនចម្រុះភាគច្រើនមកពីបរទេស មានចំនួនរហូតដល់ ២៦ក្រុមហ៊ុន កំពុងតែធ្វើការរុករក នឹងធ្វើអាជីវកម្មរ៉ែ។

តួលេខខាងលើ បានបញ្ជាក់ឱ្យដឹងក្នុងរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារលើគ្រប់វិស័យប្រចាំឆ្នាំ ២០១២ និងទិសដៅការងារសំរាប់ឆ្នាំ២០១៣ របស់សាលាខេត្តព្រះវិហារ និងមានលោក អ៊ុំ ម៉ារ៉ា ជាអភិបាលខេត្ត និង លោក ឡុង សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត ដែលពិធីនេះធ្វើឡើងកាលពីថ្ងៃទី២៣-២៤ ខែមករា ឆ្នាំ២០១៣ និងមានការ ចូលរួមបិទសន្និបាតដោយលោក ប៉ុល លឹម រដ្ឋលេខាធិការ តំណាងលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្នុងពិធីនោះដែរ លោកឧត្តមសេនីយ៍ឯក ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិ ទទួលបន្ទុកព្រំដែនប្រាសាទព្រះវិហារ ក៏បានអញ្ជើញចូលរួមផងដែរ។













លោក ប៉ុល លឹម ចូលរួមបិទសន្និបាតខេត្តព្រះវិហារ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣

តាមរបាយការណ៍ខាងលើ បានបង្ហាញថា ចាប់ពីឆ្នាំ២០០៧ រហូតមកដល់ឆ្នាំ២០១៣ គឺខេត្តព្រះវិហារ គ្រប់ស្រុក-គ្រប់តំបន់ មានក្រុមហ៊ុនបរទេសជាច្រើន បានប្រជែងគ្នាសុំអាជ្ញាប័ណ្ណពីក្រសួងឧស្សាហ៍កម្មរ៉ែ និងថាមពល ហើយធ្វើការស្វែងរក និងរុករក ធ្វើអាជីវកម្មរ៉ែយ៉ាងគគ្រឹកគគ្រេង នៅក្នុងទឹកដីខេត្តព្រះវិហារមួយនេះ។ ក្នុងចំណោមនោះមានក្រុមហ៊ុន ខ្លះកំពុងតែដំណើរការអាជីវកម្ម និងក្រុមហ៊ុនខ្លះកំពុងតែរុករក។

ក្រុមហ៊ុនទាំង២៦រួមមាន ៖ ទី១ Delcom Cambodia Pet. Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ ស្ថិតនៅតំបន់ ភ្នំដែកស្រុករវៀង, ទី២ Donghua Group Corporation Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ ស្ថិតនៅតំបន់ឃុំឆ្នា ស្រុកសែនជ័យ, ទី៣ Angkorwat Mineral Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ ស្ថិតនៅតំបន់ ស្រុកត្បែងមានជ័យ, ទី៤ Kingdom Resources Co.Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ភូមិតាបស និងភូមិស្ពៅ ស្រុកសង្គមថ្មី, ទី៥ Mekong Mining Investment Co.Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ពើកស្រុកសែនជ័យ, ទី៦ Mekong Mining Investment Co..Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ស្រុកសែនជ័យ និងស្រុកឆែប, ទី៧ Mekong Mining Investment Co.Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ភូមិជោគជ័យ ស្រុកឆែប, ទី៨ Cambodia Hau Yi Mining Co.Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ភូមិឆ្នា និងតំបន់អូរស្វាយ ស្រុកសែនជ័យ, ទី៩ Cambodia Hau Yi Mining Co.,Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ចំការស្រមូវ ក្រុងព្រះវិហារ និងស្រុកសែនជ័យ, ទី១០ Angkor Thmorpich Resources Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ស្ថិតនៅតំបន់ ឃុំស្រយង់ ស្រុកគូលែន, ទី១១ Cambodia WS Mining Industry Holding Liminted ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ស្រុករវៀង ( ប៉ែកខាងលិច ), ទី១២ Cambodia Iron & Steel Mining Industry Group Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ ស្ថិតនៅតំបន់ ស្រុករវៀង ខេត្តព្រះវិហារ, ទី១៣ Development Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១២ ស្ថិតនៅតំបន់ តំបន់ភ្នំគូសា ស្រុកឆែប, ទី១៤ Khun Sea Development Group Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្ថិតនៅតំបន់ ភ្នំស្រឡៅ ស្រុកជីក្រែង ខេត្តសៀមរាប និងស្រុកសង្គមថ្មី ខេត្តព្រះវិហារ, ទី១៥ Guangxi Nonferrous Metal Group ( Cambodia ) Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០៨ ស្ថិតនៅតំបន់កោះកែវ និងភ្នំថ្ម ស្រុករវៀង, ទី១៦ Guangxi Nonferrous Metal Group ( Cambodia ) Co., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ស្ថិតនៅតំបន់ ភ្នំត្បែងស្រុកសង្គមថ្មី, ទី១៧






Guangxi Nonferrous Metal Group ( Cambodia ) Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១១ ស្ថិតនៅតំបន់ ឃុំប្រាច ស្រុកជ័យសែន និងស្រុកឆែប, ទី១៨ Guangxi Nonferrous Metal Group ( Cam bodia ) Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ស្ថិតនៅតំបន់ភ្នំនទោង ស្រុកជ័យសែន, ទី១៩ Guangxi Nonferrous Metal Group ( Cambodia ) Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ស្ថិតនៅតំបន់កោះកែវ-ភ្នំថ្មស្រុករវៀង, ទី២០ Wing Srun Co., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១២ ស្ថិតនៅតំបន់ត្រពាំងព្រីង ស្រុកប្រាសាទបាល្ល័ង្គ និងស្រុកសង្គមថ្មី ខេត្តព្រះវិហារ, ទី២១ Wing Srun Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅតំបន់ត្រពាំងទៀម ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ, ទី២២ Kep Power Supply Co.., Ltd ប្រភេទអាជីវកម្ម រ៉ែលោហៈ មានអាជ្ញាប័ណ្ណចុះ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅតំបន់ទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ, ទី២៣ លោក គៀ ហួរ ប្រភេទអាជីវកម្ម សំណង់ថ្ម មានអាជ្ញាប័ណ្ណចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ ស្ថិតនៅតំបន់បេងកោង ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ, ទី២៤ សហគ្រាស ពុំ ម៉ៅ ចម្លាក់កូនខ្មែរ ប្រភេទអាជីវកម្ម ថ្មភក់ មានអាជ្ញាប័ណ្ណចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ ស្ថិតនៅតំបន់ត្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ, ទី២៥ ញ៉ែម ប៊ុនថា ប្រភេទអាជីវកម្ម ថ្មសំណង់ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១០ ស្ថិតនៅតំបន់ភ្នំចាស់ ភូមិភ្នំដែក ឃុំរមទម ស្រុករវៀង និងទី២៦ ហ៊ីមយន់ សិរីសម្បត្តិ ប្រភេទអាជីវកម្ម ថ្មភក់ មានអាជ្ញាប័ណ្ណចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ស្ថិតនៅតំបន់ត្រាំងដូង ភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ៕



